**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងឧស្សាហកម្ម និង សិប្បកម្ម**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ: ០២២ ស.ស.រ

## សេចក្ដីសម្រេច
## ស្ដីពី ការតែងតាំង អគ្គនាយករង

**អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

-បានឃើញព្រះរាជក្រមលេខ០៦៩៦/០៣ចុះថ្ងៃទី១៧-០៦-៩៦ស្ដីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
-បានឃើញអនុក្រឹត្យលេខ៥២អនក្រ.បក ចុះថ្ងៃទី ១៩-១២-៩៦ ស្ដីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
-បានឃើញអនុក្រឹត្យលេខ៣៨អនក្រ.បកចុះថ្ងៃទី១២-០៦-០០ស្ដីពីការកែសំរួលអនុក្រឹត្យលេខ ៥២ អនក្រ.បក
-បានឃើញអនុក្រឹត្យលេខ ៦៦៨អនក្រ.តត ចុះថ្ងៃទី ០៨-០៦-១២ ស្ដីពីការតែងតាំងអគ្គនាយក រ-ទ-ស-ភ
-បានឃើញលក្ខន្តិកៈបុគ្គលិករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលបានកែសំរួលលើកទី ៣ និងអនុម័ត ដោយក្រុមប្រឹក្សាភិបាលអាណត្តិទី ៤ នាសម័យប្រជុំលើកទី១៧ ថ្ងៃទី ២៦-០៦-១២
-លិខិតលេខ ៤៣៨MIH/២០១៤ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចុះថ្ងៃទី ១៩-០៣-១៤
-ស្មារតីប្រជុំក្រុមប្រឹក្សាភិបាល លើកទី៨ អាណត្តិទី៥ ចុះថ្ងៃទី ២០-០៣-១៤

**សម្រេច**

* * * *

**ប្រការ១:** តែងតាំង លោក **ចាន់ ពិសិដ្ឋ** ជាអគ្គនាយករង ទទួលបន្ទុក រដ្ឋបាល និងធនធានមនុស្ស ។

**ប្រការ២:** ប្រាក់បៀវត្សរ៍ និងប្រាក់បំណាច់មុខងារ របស់សាមីខ្លួន ត្រូវកំណត់តាមកំរិតដូចមានចែងក្នុងឧបសម្ព័ន្ធទី IV និងក្នុងចំណុចទី ៥-៣ នៃ ឧបសម្ព័ន្ធទី V នៃលក្ខន្តិកៈបុគ្គលិក ។

**ប្រការ៣:** នាយកដ្ឋានរ.ប.ធ , នាយកដ្ឋាន គ.ន.ហ.វ , ការិយាល័យធនធានមនុស្ស និងគ្រប់នាយកដ្ឋាន, ការិយាល័យ អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ "១" ត្រូវទទួលបន្ទុកអនុវត្តនូវសេចក្ដីសម្រេច នេះតាមភារកិច្ចរៀងៗ ខ្លួន ។

**ប្រការ៤:** សេចក្ដីសម្រេច នេះមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ , ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៤
**អគ្គនាយក**

**ស៊ឹម ស៊ីថា**

<u>កន្លែងទទួល</u>
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
-គ្រប់សមាជិកក្រុមប្រឹក្សាភិបាល"ដើម្បីជូនជ្រាប"
-ដូចប្រការ៣ "ដើម្បីអនុវត្ត - មុខការ"
-កាលប្បវត្តិ-ឯកសារ

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៤/៣៣២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងមន្ត្រីរាជការ ចំនួន ០៦ រូប ជាទីប្រឹក្សាក្រសួងឧស្សាហកម្ម និងសិប្បកម្ម :

១- ឯកឧត្តម **ឡូន នៅ** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**
២- ឯកឧត្តម **ស៊ិន សុនិសា** មានឋានៈស្មើ **អគ្គនាយក**
៣- ឯកឧត្តម **ស៊ឹម ស៊ីថា** មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន
៤- ឯកឧត្តម **ឃុត ឧត្តរារិទ្ធ** មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន
៥- លោកជំទាវ **ម៉ក់ ម៉ូលី** មានឋានៈស្មើ **អគ្គនាយក**
៦- លោកជំទាវ **ស៊ិន ឡូន** មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤*

**គួរព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**